AAPI EQUITY ALLIANCE

# 2024 VOTER GUIDE

VOTE BY NOVEMBER 5!

## រដ្ឋកាលីហ្វ័រញ៉ា

### ✅ សំណើទី ២

**គាំទ្រ:** ចេញប័ណ្ណបំណុ លសាលាចំនួន ១០ ពាន់លានដុល្លារ សទ្បប់ជួសជុល និងសាងសង់។ មូលនិធិសទ្បប់ជួសជុល តាមតម្រូវ ការរបស់សាលាចរៀន។

### ✅ សំណើទី ៣

**គាំទ្រ:** ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសម្រាប់រដ្ឋកាលីហ្វ័រញ៉ាដើម្បីធ្វើឱ្យអាពាហ៍ពិពាហ៍ ក្លាយជាសិទ្ធិជា មូលដ្ឋានសម្រាប់ទាំងអស់ គ្នា។ ពលរដ្ឋគ្រប់រូបនៅកាលីហ្វ័រញ៉ា គួរតែមានសេរីភាពក្នុងការរៀ បការ ដែលរួមទាំងជនជាតិអាមេរិកាំងចំនួន ៦៦.០០០នាក់ ដែលមានដើមកំណើតអាស៊ី និងដើមកំណើតពីបណ្ដាកោះ នានានៅមហាសមុទ្រប៉ាស៊ីហ្វិក (AAPIs) ដែលរស់ នៅក្នុងរដ្ឋនេះ ដែលត្រូវបានកំណត់អត្តសញ្ញាណថាជា ជនដែលមានភេទខ្ទើយ ដូរភេទ ឬគ្មានការកំណត់ភេទច្បាស់ លាស់ (LGBTQ)។

### ✅ សំណើទី ៤

**គាំទ្រ:** ចេញប័ណ្ណបំណុលចំនួន ១០ ពាន់លានដុល្លារ សម្រាប់គម្រោងប្រែប្រួលអាកាសធាតុ និងបរិស្ថាន ដូចជា គម្រោងកែច្នៃទឹក កខ្វក់ឡើងវិញ ការទប់ស្កាត់ភ្លើងឆេះ ព្រៃ និងការផ្ដល់មូលនិធិ សម្រាប់អភិវឌ្ឍន៍ថាមពលកកើតឡើងវិញ។ AAPIs ត្រូវការ ជំនួយសង្គ្រោះ នៅចំពោះ មុខ ផលប៉ះ ពាល់នៃការប្រែប្រួលអាកាសធាតុ។

### ✅ សំណើ៥

**គាំទ្រ:** បន្ទាបកម្រិតចាំបាច់សម្រាប់ការអនុម័តពីសម្លេងឆ្នោតចំនួន ពីរភាគបី មកត្រឹម ៥៥% សម្រាប់ប័ណ្ណបំណុលក្នុងស្រុក ដែល ផ្ដល់មូលនិធិសម្រាប់ជាជំនួយក្នុងការផ្ដល់លំនៅដ្ឋានដែលមានតម្លៃសមរម្យ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ផ្សេង ទៀ ត។ បង្កលក្ខណៈងាយស្រួលជាងមុនសម្រាប់ទីក្រុង និងខោនធីក្នុងការដោះ ស្រាយវិបត្តិលំនៅដ្ឋាន ជាមួយការគាំទ្រដោយសម្លេងភាគច្រើននៅក្នុងការបោះ ឆ្នោត។

### ✅ សំណើ៦

**គាំទ្រ:** ហាមឃាត់ពលកម្មដោយបង្ខំ ដែលជាការដាក់ទណ្ឌកម្មនៅក្នុងពន្ធនាគាររដ្ឋកាលីហ្វ័រញ៉ា ចំពោះ អ្នកទោសពីបទព្រហ្មទណ្ឌ។ ពលកម្មដោយបង្ខំ ជាទម្រង់មួយនៃទាសភាព ដែលនាំឱ្យបាត់បង់លក្ខណៈ ស្មើភាព បង្កើតនូវភាពមិនចាំបាច់ និងអយុត្តិធម៌ សម្រាប់ពលរដ្ឋកាលីហ្វ័រញ៉ាដែលកំពុងជាប់ឃុំ។

### ✅ សំណើ៣២

**គាំទ្រ:** ដំឡើងប្រាក់ឈ្នួលអប្បបរមានៅក្នុងរដ្ឋនេះ ឱ្យដល់យ៉ាងហោចណាស់ ១៨ដុល្លារ/ម៉ោង គិតត្រឹមឆ្នាំ២០២៦។ ឈានឱ្យកាន់ តែជិត ២៧ ដុល្លា/ម៉ោង ដែលជាកម្រិតប្រាក់ឈ្នួលចាំបាច់សម្រាប់ AAPIs ដែលធ្វើការ និងដែលជាអ្នកប្រឈមការលំបាក ដោយសារថ្លៃចំណាយខ្ពស់សម្រាប់ការរស់នៅ។

### ✅ សំណើ៣៣

**គាំទ្រ:** ផ្ដល់ឱ្យអាជ្ញាធរទីក្រុង និងខោនធី ជំនួសឱ្យការផ្ដល់ទៅអាជ្ញាធររដ្ឋកាលីហ្វ័រញ៉ា នូវអំណាចក្នុងសម្រេចចិត្ត អំពីការគ្រប់គ្រង ថ្លៃជួលលំនៅដ្ឋាននៅក្នុងសហគមន៍របស់ខ្លួន។ ការគ្រប់គ្រងថ្លៃជួលអាចជួយ AAPIs ដែលមានប្រាក់ចំណូលទាប និងដែល មិនអាចបង្កើនប្រាក់ចំណូលរបស់ខ្លួនឱ្យទាន់កំណើនថ្លៃជួល ដើម្បីអាចរស់នៅទីកន្លែងមានថ្លៃជួលខ្ពស់ដូចជាឡូសអេនជឺ ឡែស។

### ❌ សំណើ៣៤

**ជំទាស់:** រឹតត្បិតចំពោះ អ្នកផ្ដល់សេវាថែទាំសុខភាពមួយចំនួន ដែលជាស្ថាប័នមិនស្វែងរកប្រាក់ចំណេញ ក្នុងការចំណាយលើការទិញ ឱសថតាមវេជ្ជបញ្ជាដែលមានការបញ្ចុះ ថ្លៃ សម្រាប់សកម្មភាពនយោបាយ។ នេះ ជាការប៉ុនប៉ងរបស់សមាគមផ្ទះ ល្វែង កាលីហ្វ័រញ៉ា ដើម្បីបញ្ឈប់ស្ថាប័នមូលនិធិ ថែទាំសុខភាពអ្នកមានជំងឺអេដស៍ពីការចំណាយប្រាក់លើសកម្មភាពនយោបាយ មកលើកកម្ពស់ការគ្រប់គ្រងថ្លៃជួល។

### ❌ សំណើ៣៦

**ជំទាស់:** បង្កើនការពិន័យព្រហ្មទណ្ឌចំពោះ បទល្មើសគ្រឿ ងញៀ ន និងចោរកម្ម។ នឹងនាំឱ្យមនុស្សកាន់តែច្រើនជាប់ពន្ធនាគារ ដែល ជា បន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់អ្នកបង់ពន្ធ ដោយគ្មានភស្តុតាងដែលបញ្ជាក់ថា វិធានការនេះ កាត់បន្ថយបទល្មើសព្រហ្មទណ្ឌ ឡើយ និងមានភស្តុតាងដែលថា នេះ ជាវិធានការរើសអើងខាងជាតិសាសន៍។

## ខោនធីឡូសអេនជឺឡេស

### ✅ វិធានការ A

**គាំទ្រ:** ការកំណត់ពន្ធ កន្លះ សេនសម្រាប់ការលក់ នៅក្នុងខោនធីឡូសអែនជឺឡេស ដើម្បីផ្ដល់ជាមូលនិធិសម្រាប់លំនៅដ្ឋានដែល មានតម្លៃសមរម្យ និងការថែទាំពលរដ្ឋដែលគ្មានផ្ទះ សម្បែង ហើយកំពុងជួបបញ្ហាផ្លូវចិត្ត។ អាជ្ញាធរខោនធីឡូសអែនជឺឡេស ត្រូវការប្រភពថវិកាដែលមានស្ថិរភាព ដើម្បីដោះស្រាយវិបត្តិលំនៅដ្ឋាន។

### ✅ វិធានការ E

**គាំទ្រ:** ការកំណត់ពន្ធចំនួនប្រាំមួយសេន លើក្បាលដី នៅក្នុងទីក្រុងចំនួន ៥៩ និងតំបន់ដែលមិនបានរួមបញ្ចូល នៅក្នុងខោនធីឡូសអែនជឺឡេស ដែលទទួលសេវាពីនាយកដ្ឋានប្រយុទ្ធប្រឆាំងអគ្គីភ័យ។ ទឹកប្រាក់បានពីពន្ធនេះ នឹងត្រូវប្រើ ដើម្បីជួលអ្នកពន្លត់ អគ្គីភ័យ និងទិញឧបករណ៍នានា ដើម្បីឱ្យពលរដ្ឋមានលទ្ធភាពទទួលបានសេវាសង្គ្រោះ ជីវិតដែលពួកគេ ត្រូវការជាចាំបាច់។

### ✅ វិធានការ G

**គាំទ្រ:** ពង្រីកសមាសភាពគណៈ អភិបាលពី ៥ ទៅ ៩ រូប ហើយតំណែងនាយកប្រតិបត្តិត្រូវតែបានពីការបោះ ឆ្នោត។ ធ្វើឱ្យខោនធី ដ៏ធំបំផុតនៅក្នុងប្រទេសនេះ កាន់តែមានលក្ខណៈ ប្រជាធិបតេយ្យ គណនេយ្យភាព និងតំណាងឱ្យ AAPIs ចំនួន ១,៦ លាន នាក់ ដែលរស់នៅទីនេះ ។

## ទីក្រុងឡូសអែនជឺឡេស

### ✅ វិសោធនកម្មធម្មនុញ្ញ DD

**គាំទ្រ:** បង្កើតគណៈ កម្មការឯករាជ្យក្នុងចំណោមប្រជាពលរដ្ឋចម្រុះ ជាតិសាសន៍ ដើម្បីគូសបន្ទាត់សង្កាត់ ទាំងដប់ប្រាំ ដែលតំណាង ដោយក្រុមប្រឹក្សាទីក្រុងឡូសអែនជឺឡេស។ អ្នកនយោបាយមិនគួរកំណត់ព្រំដែននៃសង្កាត់របស់ខ្លួន ដើម្បីបញ្ចូលតែពលរដ្ឋ ដែលបោះ ឆ្នោតគាំទ្រខ្លួននោះ ឡើយ។

### ✅ វិសោធនកម្មធម្មនុញ្ញ LL

**គាំទ្រ:** បង្កើតគណៈ កម្មការឯករាជ្យក្នុងចំណោមប្រជាពលរដ្ឋចម្រុះ ជាតិសាសន៍ ដើម្បីគូសបន្ទាត់សង្កាត់ ទាំងប្រាំពីរ ដែលតំណាង ដោយក្រុមប្រឹក្សាអប់រំ LAUSD។ អ្នកនយោបាយមិនគួរកំណត់ព្រំដែននៃសង្កាត់របស់ខ្លួន ដើម្បីបញ្ចូលតែពលរដ្ឋដែលបោះ ឆ្នោតគាំទ្រខ្លួននោះ ឡើយ។

### ✅ វិសោធនកម្មធម្មនុញ្ញ HH

**គាំទ្រ:** គូសបញ្ជាក់អំពីអំណាចនៃអ្នកចាត់ចែងគ្រប់គ្រងកិច្ចការទីក្រុង និងមេធាវីរបស់ទីក្រុង ក្នុងចំណោមការកែប្រែផ្សេងទៀ ត ខាង បច្ចេកទេស ចំពោះធម្មនុញ្ញសម្រាប់ទីក្រុង។ ជួយបំភ្លឺពីអំណាចរបស់មន្ត្រីបម្រើការនៅសាលាក្រុង។

### ✅ វិសោធនកម្មធម្មនុញ្ញ II

**គាំទ្រ:** ការពារបុគ្គលិកសាលាក្រុងពីការរើសអើង ដោយសារតែអត្តសញ្ញាណយេនឌ័រ ក្នុងចំណោមការកែប្រែផ្សេងទៀ តខាង បច្ចេកទេសនៅក្នុងធម្មនុញ្ញសម្រាប់ទីក្រុង។ ជួយរដ្ឋបាលសាលាក្រុង ឱ្យបន្តការងារសម្រាប់កិច្ចការទីក្រុង។

ស្ថាប័នសម្ព័ន្ធសមធម៌ *AAPI* មិនទទួលយកមុខតំណែងណាមួយនៅ *California Prop 35* និង វិសោធនកម្មធម្មនុញ្ញ ទីក្រុងឡូសអែនជឺឡេស នៃ *ER* និង *FF* ឡើយ។

**Ad paid for by AAPI Equity Alliance, 905 E 8th St, Los Angeles. Additional information available at ethics.lacity.org**